REDD+ CAMBODIA

# CAMBODIA REDD+ PROGRAMME

- ចំណងជើងបទបង្ហាញ៖ **ការប្រែប្រួលអាកាសធាតុ និង រ៉េដបូក**
- ទីកន្លែង៖ សណ្ឋាគាររ៉ាហ្វល ឡឺរ៉ូយ៉ាល់
- កាលបរិច្ឆេទ៖ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣



# មាតិកា

- ការប្រែប្រួលអាកាសធាតុ និង **រ៉េដបូក**
- តើ **រ៉េដបូក** ជាអ្វី?
- ស្ថានភាពនៃការចរចា និងហិរញ្ញប្បទាន **រ៉េដបូក** លើសកលលោក
- ហេតុអ្វីចាំបាច់មាន **រ៉េដបូក** នៅកម្ពុជា? តើវារួមចំណែកបែបណាក្នុងអភិបាលកិច្ចព្រៃឈើនៅក្រោម FA, GDANCP និង FiA?





# ការប្រែប្រួលអាកាសធាតុ និង រ៉េដបូក

- ឥទ្ធិពលរបស់មនុស្សមកលើប្រព័ន្ធអាកាសធាតុបានបង្ហាញច្បាស់
- ការបំភាយឧស្ម័នផ្ទះកញ្ចក់បន្តធ្វើឲ្យមានការឡើងកំដៅផែនដីថែមទៀត និងការប្រែប្រួលនានានៃសមាសភាគទាំងអស់ ក្នុងប្រព័ន្ធអាកាសធាតុ
- ការកំហិតលើការប្រែប្រួលអាកាសធាតុ នឹងទាមទារឲ្យមានការកាត់បន្ថយយ៉ាងច្រើននូវការបំភាយឧឧស្ម័នផ្ទះកញ្ចក់

របាយការណ៍វាយតម្លៃលើកទី ៥ នៃ IPCC 2013






ការបាត់បង់ព្រៃឈើលើពិភពលោក និងការរេចរឹលព្រៃឈើរួម
ចំណែកប្រមាណ ១២% នៃការបំភាយឧស្ម័នសរុបលើពិភពលោក

# រ៉េដបូក

- ផ្តល់ការលើកទឹកចិត្តខាងសេដ្ឋកិច្ច សម្រាប់កាត់បន្ថយការបំភាយឧស្ម័នពី ការបាត់បង់ និងការរេចរឹលព្រៃឈើ និងការបង្កើតព្រៃឈើថ្មីៗ

- ប្រការនេះអាចកើតមាន តាមរយៈកំណែលម្អផែនការប្រើប្រាស់ដី ការគ្រប់គ្រងព្រៃឈើបានប្រសើរជាងមុន ការប្រើប្រាស់ធនធានព្រៃឈើប្រកបដោយប្រសិទ្ធភាពខ្ពស់ជាងមុន។ល។





# រេដបូក

- **រេដបូក** គឺជាឱកាសមួយដើម្បីទទួលផលពីការគាំទ្រជាអន្តរជាតិ ដល់កិច្ចប្រឹងប្រែងសកលលោក ដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុ ទន្ទឹមនឹងលើកកំពស់ការគ្រប់គ្រងព្រៃឈើ ដើម្បីជាប្រយោជន៍នៃសេដ្ឋកិច្ច និងប្រជាជនរបស់ខ្លួន។





# តើយើងត្រូវធ្វើអ្វីខ្លះដើម្បី ទទួលផលពី រ៉េដបូក?





# COP15 ស្នើប្រទេសនានា៖

- (a) កំណត់អត្តសញ្ញាណកត្តាជម្រុញនៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ដែលនាំឲ្យមានការបំភាយឧស្ម័ន និងមធ្យោបាយសម្រាប់ការដោះស្រាយកត្តាទាំងនោះ។

- (b) កំណត់អត្តសញ្ញាណសកម្មភាពនានានៅក្នុងប្រទេស ដែលនាំមកនូវការកាត់បន្ថយការបំភាយ និងបង្កើនសម្រូប និងរក្សាតុល្យភាពស្តុកកាបូនព្រៃឈើ





# ដំណាក់កាលទាំងបីនៃ រ៉េដបូក

ដំហាន ១៖ ការត្រៀមលក្ខណៈ

ដំហាន ២៖ ការអនុវត្តគោលនយោបាយ និងវិធានការនានា

ដំហាន ៣៖ ការទូទាត់ដែលផ្អែកលើគុណផល





# ដែបូក

នៅក្នុងដំណាក់កាលនៃការត្រៀមខ្លួន កម្ពុជានឹងបង្កើតប្រព័ន្ធពិនិត្យតាមដានព្រៃឈើជាតិ និងអាចតាមដានព្រៃឈើរបស់ខ្លួន និងបង្កើតកម្រិតយោងរបស់ជាតិ....



# ការបាត់បង់ព្រៃឈើអាចរកឃើញតាម
# រូបថតពីផ្កាយរណប



# បន្ទាប់មកការបំភាយក៏អាចប៉ាន់ស្មានបាន

សម្រាប់តែជាការបង្ហាញ

| ថ្នាក់ព្រៃឈើ | បរិមាណកាបូនជាមធ្យម តោន C/ហ.ត | ការបាត់បង់ប្រចាំឆ្នាំ ហ.ត | ការបាត់បង់កាបូនប្រចាំឆ្នាំ តោន C |
|---|---|---|---|
| X | 150 | 345 | 51.750 |
| Y | 120 | 125 | 15.000 |
| Z | 90 | 2.000 | 180.000 |
| | | | |
| | | | |
| សរុប | | 2.470 | 246.750 |





# ការបូនស្តុកនៃព្រៃឈើឈរក៏អាចតាមដានបានតាមរយៈ NFI



# កាបូនស្តុកនៃព្រៃឈើអាចតាមដានបាន

សម្រាប់តែជាការបង្ហាញ

| | | 2015 | 2020 | |
|---|---|---|---|---|
| | ព្រៃឈើ (ហ.ត) | 10.000.000 | 9.850.000 | |
| 1 | ជីវម៉ាសដែលរស់នៅខ្ពស់ផុតពីផ្ទៃដី | 150.000 | 140.000 | |
| 2 | ជីវម៉ាសដែលរស់នៅក្នុងដី | 50.000 | 45.000 | |
| 3 | កំទេចកំទី | 25.000 | 24.000 | |
| 4 | ឈើងាប់ | 15.000 | 15.000 | |
| 5 | ដី | 50.000 | 47.000 | |
| | សរុប | 290.000 | 271.000 | |
| | ការប្រែប្រួលប្រចាំឆ្នាំ | | -3.800 tC | |

ការបំភាយ
3.800*3,67=
13.946 $tCO_2$/ឆ្នាំ

PROGRAMME



# តាមរយៈព័ត៌មាននេះ យើងអាចប៉ាន់ស្មានការបំភាយប្រចាំឆ្នាំ



# និងបង្កើតកម្រិតយោង



# យុទ្ធសាស្ត្រជាតិ រ៉េដបូក

នៅក្នុងដំណាក់កាលត្រៀមលក្ខណៈ កម្ពុជាគួរតែបង្កើតយុទ្ធសាស្ត្រ **រ៉េដបូក** ជាតិ ដើម្បីដោះស្រាយកត្តាជម្រុញការបាត់បង់ព្រៃឈើ និងការរេចរឹល ព្រៃឈើ ដែលនាំមកនូវការកាត់បន្ថយការបំភាយ។





# ប្រការនេះនឹងផ្តល់ការកាត់បន្ថយការបំភាយ



# លក្ខខណ្ឌសម្រាប់ទទួលការទូទាត់ដែលផ្អែកលើលទ្ធផល

- យុទ្ធសាស្ត្រជាតិ **រ៉េដបូក**
- កម្រិតយោងថ្នាក់ជាតិ * អនុម័តនៅក្នុងដំណើរការ UNFCCC
- ប្រព័ន្ធពិនិត្យតាមដានព្រៃឈើជាតិ
- លទ្ធផលពីការដាក់ជូនរបស់ប្រទេស តាមរយៈរបាយការណ៍បច្ចុប្បន្នភាពប្រចាំពីរឆ្នាំម្តង និងវិភាគដោយក្រុមពិនិត្យបច្ចេកទេសនៃ UNFCCC
- របាយការណ៍ជាតិស្តីពីកិច្ចការពារសុវត្ថិភាព

* ដោយថ្នាក់ក្រោមជាតិជាវិធានការបណ្តោះអាសន្ន





# ស្ថានភាពនៃការចរចារ និង ហិរញ្ញប្បទាន រ៉េដបូក លើ ពិភពលោក



# សេចក្តីសម្រេចរបស់ UNFCCC








# សេចក្ដីសម្រេចរបស់ UNFCCC

នៅក្រោយ COP19 ឥឡូវនេះ យើងមានសេចក្ដីសម្រេចនានាស្ដីពីគ្រប់ធាតុផ្សំទាំងអស់ដែលចាំបាច់សម្រាប់ទទួលមូលនិធិដែលផ្អែកលើលទ្ធផល។

ឥឡូវនេះ កិច្ចការនេះអាស្រ័យលើប្រទេសនានា ប្រសិនបើពួកគេចង់ប្រើប្រាស់ឱកាសដើម្បីទទួលបានការទូទាត់សម្រាប់ការកាត់បន្ថយការបំភាយដែលបានផ្ទៀងផ្ទាត់





# ហិរញ្ញប្បទាន រ៉េដបូក នៅមុនឆ្នាំ ២០២០

មូលនិធិកាបូន FCPF ៤០០-៦០០លានដុល្លាអាមេរិក

មូលនិធិជីវៈកាបូន ២៨០លានដុល្លាអាមេរិក

កិច្ចព្រមព្រៀងទ្វេភាគី ដូចជា អាល្លឺម៉ង់ ន័រវេស JCM ?

មូលនិធិអាកាសធាតុបៃតង ?

ការសន្និដ្ឋាន៖ ពុំចាំបាច់រង់ចាំរហូតដល់ឆ្នាំ ២០២០ឡើយ





# មិនមែនអ្វីទាំងអស់សុក្រិត្យតាំងពីដំបូងឡើយ

ឯកភាពថាវិធានជាជំហានៗក្នុងការកំណត់កម្រិតបំភាយយោងសម្រាប់ព្រៃឈើជាតិនិង/ឬកម្រិតយោងព្រៃឈើ អាចមានប្រយោជន៍ ដោយសារអាចឲ្យភាគីនានាកែលម្អកម្រិតយោងបំភាយសម្រាប់ព្រៃឈើ និង/ឬកម្រិតយោងព្រៃឈើ ដោយរួមបញ្ចូលទិន្នន័យប្រសើរជាងមុន វិធីសាស្រ្តកែលម្អប្រសើរជាងមុន និងក្នុងករណីសមស្រប អាចបញ្ចូលមណ្ឌលកាបូនបន្ថែមផងដែរ

(សេចក្តីសម្រេចក្នុង COP 17)





# ជំហានបន្ទាប់

1. វិភាគកត្តាជម្រុញ និងកំណត់តអត្តសញ្ញាណវិធីនានាដើម្បីដោះស្រាយ
2. រួមបញ្ចូលចំណុចនេះទៅក្នុងយុទ្ធសាស្ត្រជាតិ **រ៉េដបូក**
3. បង្កើតប្រព័ន្ធជាតិមួយសម្រាប់ការពារសុវត្ថិភាព និងប្រព័ន្ធព័ត៌មាន
4. បង្កើតប្រព័ន្ធពិនិត្យតាមដានព្រៃឈើ
5. បង្កើតកម្រិតយោងបំភាយសម្រាប់ព្រៃឈើ
6. បង្កើតមូលនិធិដើម្បីទទួលហិរញ្ញវត្ថុដែលផ្អែកលើលទ្ធផល
7. បង្កើតយន្តការបែងចែកផល





# ហិរញ្ញប្បទានផ្អែកលើលទ្ធផលពី រ៉េដបូក

តើកម្ពុជាត្រូវការរយៈពេលប៉ុន្មានទើបអាចចូលរួមនៅក្នុងកម្មវិធីកាត់បន្ថយការបំភាយ?

ចំណុចនេះ អាស្រ័យជាសំខាន់លើកម្ពុជាខ្លួនឯងផ្ទាល់

ការពិនិត្យតាមដានព្រៃឈើនឹងបន្តកែលម្អជាច្រើនឆ្នាំខាងមុខទៀត ប៉ុន្តែនេះមិនមែនមានន័យថាកម្ពុជាមិនអាចផ្តល់ការកាត់បន្ថយការបំភាយដែលបានផ្ទៀងផ្ទាត់នោះទេ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។

**CAMBODIA REDD+ NATIONAL PROGRAMME**



# ប្រទេសនានាឥឡូវនេះអាចទទួលកម្រៃពី ការកាត់បន្ថយនៃការបំភាយដែលបានផ្ទៀងផ្ទាត់



# ហេតុអ្វីចាំបាច់មាន **រ៉េដបូក** នៅកម្ពុជា?

ការសិក្សាថ្មីមួយបានសន្និដ្ឋានថា កម្ពុជាមានអត្រាបាត់បង់ព្រៃឈើខ្ពស់ជាងគេ
នៅលំដាប់ទី ៥ក្នុងពិភពលោក

កម្ពុជាក៏មានភាគរយវិសាលភាពព្រៃឈើខ្ពស់ជាងគេនៅអាស៊ីអាគ្នេយ៍ផងដែរ

**រ៉េដបូក** នឹងមិនបញ្ឈប់ការបាត់បង់ព្រៃឈើឡើយ ប៉ុន្តែវាផ្ដល់ជម្រើសផ្សេងនៃ
ការទូទាត់សម្រាប់ការអភិរក្សព្រៃឈើ (កាត់បន្ថយការបំភាយ)





# តើរួមចំណែកបែបណាក្នុងអភិបាលកិច្ចព្រៃឈើនៅក្រោម FA, GDANCP និង FiA?

**រ៉េដបូក** ទាមទារឲ្យមានអភិបាលកិច្ចព្រៃឈើបានល្អ

**រ៉េដបូក** ផ្អែកលើលទ្ធផល។ នេះមានន័យថា កម្ពុជានឹងទទួលការលើកទឹកចិត្តស្របតាមលទ្ធផល។

ផលចំណូលទំនងជាត្រូវប្រើប្រាស់សម្រាប់គ្រប់គ្រង **រ៉េដបូក** ដែលរាប់បញ្ចូលថ្លៃចំណាយ ដូចជា ការពិនិត្យតាមដាន និងរាយការណ៍អំពីលទ្ធផល អភិបាលកិច្ចព្រៃឈើ ប៉ុន្តែ ដើម្បីផ្តល់ជាការលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធផងដែរ ដែលរួមទាំង ស្ថាប័នពាក់ព័ន្ធនានាផងដែរ។





# តើបែងចែកផលចំណូលបែបណា?

ដើម្បីទទួលបានលទ្ធផល អ្នកពាក់ព័ន្ធសំខាន់ៗគួរតែមានការលើកទឹកចិត្ត ដើម្បីកាត់បន្ថយការបំភាយពីការបាត់បង់ និងការរេចរឹលព្រៃឈើ និង ការលើកទឹកចិត្តសម្រាប់បង្កើតព្រៃឈើថ្មីៗ។

គេចាំបាច់ត្រូវបង្កើតយន្តការចែកផល ដែលរួមទាំង វិធានការតម្លាភាព ដើម្បីធានាថា អ្នកពាក់ព័ន្ធនានាមានការលើកទឹកចិត្តដើម្បីរួមចំណែក។



# តើបែងចែកផលចំណូលបែបណា?

ប្រសិនបើគ្មានការលើកទឹកចិត្ត តើធ្វើបែបណាទើបយើងអាចរំពឹងថា អ្នកពាក់ព័ន្ធកែប្រែទម្លាប់អនុវត្ត?

ការលើកទឹកចិត្តសម្រាប់រដ្ឋាភិបាល សហគមន៍ ម្ចាស់ដីឯកជន ។ល។ អាចកែលម្អការគ្រប់គ្រងព្រៃឈើ។

នេះជាអ្វីដែល **រ៉េដបូក** កំពុងព្យាយាមធ្វើ។





# សូមអរគុណ!

Peter Iversen

Email: peter.iversen@undp.org

Website: www.cambodia-redd.org / http://www.un-redd.org



